# ឈ្មោះ បន្ទាយស្រី

បន្ទាយស្រី ជាប្រាសាទដែលសាងនៅឆ្នាំ៩៦៧ ពោលគឺស្ថិតនៅចុងរាជ្យព្រះបាទ រាជេន្ទ្រវរ្ម័នទី២ (គ.ស. ៩៤៤~៩៦៨) និងដើមរាជ្យ ព្រះបាទ ជ័យវរ្ម័នទី៥ (គ.ស ៩៦៨~១០០១) ដោយព្រាហ្មណ៍ ឬជាព្រះរាជគ្រូម្នាក់ឈ្មោះ យជ្ញវរាហ (Yajñavarāha) ក្នុងក្រុងបុរាណឈ្មោះ ឥស្វរបុរ (ក្រុងឥស្វរ)។ ឈ្មោះរបស់ព្រាហ្មណ៍នេះភ្ជាប់ទៅនឹងអវតារមួយក្នុងចំណោមអវតារទាំង១០របស់ព្រះនារាយណ៍ គឺជ្រូកព្រៃ (សំ. varāha)។ ប៉ុន្តែទេពសំខាន់ដែលឧទ្ទិសថ្វាយ គឺព្រះឥសូរ ដូចក្នុងសិលាចារឹក (K.842) បានចារឈ្មោះដើមរបស់ប្រាសាទក្នុងទម្រង់ជាលិង្គនាម ស្រីត្រិភុវនមហេស្វរ (ស្រីត្រីភូវនមហេសូរ = ម្ចាស់នៃលោកទាំងបី)។

ឈ្មោះ “បន្ទាយស្រី” នេះ បើមើលនៅក្នុងសៀវភៅមគ្គុទេសន៍ទាំងភាសាបរទេសក្តី ភាសាខ្មែរក្តី ភាគច្រើនបកស្រាយន័យ ឬប្រែថា "បន្ទាយរបស់ស្រី (Fortress or Citadel of Women)"។ ន័យនៅក្នុងសៀវភៅមគ្គុទេសន៍ទាំងនោះមិនត្រឹមត្រូវទៅនឹងន័យដើម ឬពិតប្រាកដរបស់ឈ្មោះប្រាសាទនោះឡើយ។ ខ្ញុំសូមបកស្រាយដូចខាងក្រោម៖

ដំបូង យើងត្រូវយល់អំពីពាក្យ “បន្ទាយ”។ "បន្ទាយ" មកពីកិរិយាស័ព្ទ "ផ្ទាយ" មានន័យថា "ទប់, ទ្រ, ការពារ"។ "បន្ទាយ" ជាពាក្យ ឬជាឈ្មោះទូទៅដែលអ្នកស្រុកហៅសំដៅទៅលើទីតាំង ប្រាសាទ ក្រុងចាស់ ឬភូមិដែលមាន "ទំនប់, របងជញ្ជាំង, កំពែង" ព័ទ្ធជុំវិញ។ ឧ. បន្ទាយព្រៃនគរ (ឈ្មោះក្រុងចាស់មួយនៅសម័យមុនអង្គរ, សព្វថ្ងៃស្ថិតនៅខេត្តត្បូងឃ្មុំ), បន្ទាយលង្វែក (ឈ្មោះរាជធានីខ្មែរនៅសតវត្សទី១៦), បន្ទាយក្តី, បន្ទាយស្រី, បន្ទាយសម្រែ, បន្ទាយធំ, បន្ទាយឆ្មារ, បន្ទាយព្រហ្ម (បន្ទាយតាព្រហ្ម, បាពាំងហៅ ប្រាសាទតាព្រហ្ម), បន្ទាយបាកាន (បារាំងហៅ ព្រះខ័នកំពង់ស្វាយ) ជាដើម។ ល។ សូមបញ្ជាក់ថា កាលណាអ្នកស្រុកហៅ បន្ទាយនេះ ឬបន្ទាយនោះហើយ គាត់មិនប្រើពាក្យ "ប្រាសាទ" នៅពីមុខឡើយ។ ឧទាហរណ៍ គាត់និយាយថា "ទៅបន្ទាយក្តី" គាត់មិននិយាយថា "ទៅប្រាសាទបន្ទាយក្តី" ទេ។ ដូច្នេះបើសរសេរ ឬហៅ "បន្ទាយស្រី" មិនចាំបាច់ដាក់ពាក្យ “ប្រាសាទ” ពីមុខឡើយ ពោលគឺ "បន្ទាយ" មានន័យសំដៅទៅនឹងពាក្យ "ប្រាសាទ" ស្រេចហើយ។

ញឹម សុធារិទ្ធ
សាកលវិទ្យាល័យសូហ៊ីយ៉ា

អ្វីដែលយើងត្រូវពិចារណា គឺពាក្យ "ស្រី"។ "ស្រី" នៅក្នុងន័យរបស់ប្រាសាទនេះ យើងគិតថាមិនសំដៅទៅលើអត្ថន័យ "ស្ត្រី ឬ ស្រី" ដែលជាមនុស្សស្រីនោះទេ។ ពាក្យ "ស្រី" នេះគឺមានន័យថា "ដែលខ្ពង់ខ្ពស់", "ដែលអស្ចារ្យ", "ដែលប្រសើរ", "ដែលមង្គល"។ ពាក្យនេះមានប្រើច្រើននៅក្នុងសិលាចារឹកដោយដាក់នៅពីមុខឈ្មោះរបស់មនុស្ស (ព្រះរាជា) ព្រះ រាជធានី និងទីកន្លែងផ្សេងៗទៀត។ ឧ. ស្រីកម្រង់តេង ជគត ត រាជ (នាមរបស់ទេព), ស្រីជ័យវម្ម័...(នាមរបស់ព្រះរាជា), ស្រីយសោធរ (ឈ្មោះរាជធានីបុរាណរបស់អង្គរ), ស្រីមង្គល (ឈ្មោះមនុស្សប្រុស), ស្រីសោភ័ណ (ក្រុងនៅខេត្តបន្ទាយមានជ័យ សៀមហៅ ស៊ីសុផុន), ស្រីលង្កា (ឈ្មោះរបស់ប្រទេសស្រីលង្កា)។ល។

ដូច្នេះឈ្មោះ “បន្ទាយស្រី” គឺបង្ហាញទៅលើន័យដែលប្រសើរ ដែលល្អអស្ចារ្យ ដែលខ្ពង់ខ្ពស់។ ជាពិសេសគឺសំដៅលើស្ថាបត្យកម្ម ស្នាដៃក្បាច់ចម្លាក់ដ៏ប្រណិតដ៏អស្ចារ្យ ដ៏សម្បើម ដ៏ឥតខ្ចោះរបស់ប្រាសាទ ជាជាងមានន័យថា "បន្ទាយរបស់មនុស្សស្រី"។ ន័យរបស់ “បន្ទាយស្រី” ក៏ភ្ជាប់ទៅនឹងឈ្មោះដើមរបស់ប្រាសាទនេះផ្ទាល់ដែរ ពោលគឺ “ស្រីត្រិភុវនមហេស្វរ” (ស្រីត្រីភូវនមហេសូរ = ម្ចាស់នៃលោកទាំងបី)។

ពាក្យ "ស្រី" មានន័យផ្សេងទៀត ដូចជា "បាយស្រី" (ដែលគេសព្វថ្ងៃច្រើនហៅបាយសី), "ជ័យស្រី" (ឈ្មោះដើមរបស់ប្រាសាទព្រះខ័ន), រាជស្រី (ឈ្មោះដើមរបស់ប្រាសាទនាគព័ន្ធ), “ស្រី” ក៏មានន័យថា “ម្ទូ” ដែរ ឧទាហរណ៍ “ស្ដេចសោយព្រះស្រី” មានន័យថា “ស្ដេចសោយម្ទូ” ជាដើម ។ ល។



បន្ទាយស្រី

ញឹម សុជាវិទ្ធ
សាកលវិទ្យាល័យសូហ្វីយ៉ា